**ឧបសម្ព័ន្ធភ្ជាប់លិខិតលេខ ០៤០ ស.ជ.ណ/គ.ជ.អ.ប ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ស្ដីពីការបន្តអនុវត្ត ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌគោលដៅនៃអង្គភាពផ្ដល់សេវា និងផែនការ អនុវត្តគណនេយ្យភាពសង្គមជំណាក់កាលទី២នៅរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ នៃរាជធានី ខេត្ត**

# តួនាទី ភារកិច្ចក្នុងការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម របស់ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ

ក).**តួអង្គអនុវត្តការងារគណនេយ្យភាពសង្គម** (I-SAF) មានពីរផ្នែក **គឺផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ**

- **ផ្នែកផ្គត់ផ្គង់** ( Supply side)ជាតួអង្គរដ្ឋ មានក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្ដល់សេវា និង
- **ផ្នែកតម្រូវការ** ( Demand side) ជាតួអង្គមិនមែនរដ្ឋ (ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល)។

I-**ផ្នែកផ្គត់ផ្គង់** (Supply side)

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គភាពផ្ដល់សេវា (ឃុំ សង្កាត់ សាលាបឋមសិក្សា និង មណ្ឌលសុខភាព) មានតួនាទី ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

➢ **រដ្ឋបាលរាជធានី ខេត្ត៖** គាំទ្រដំណើរការអនុវត្តការងារគណនេយ្យភាពសង្គម មានដូចខាក្រោម៖

១).រៀបចំសេចក្ដីសម្រេចបង្កើត និងចាត់តាំងមន្ត្រីបង្គោលគណនេយ្យភាពសង្គម និងក្រុមការងារ គណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត។

២).ផ្សព្វផ្សាយផែនការអនុវត្តគណនេយ្យភាពសង្គមដល់ស្ថាប័នពាក់ព័ន្ធ

៣).រៀបចំបណ្ដុះបណ្ដាលបច្ចេកទេស ស្ដីពីការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម ដល់មន្ត្រីបង្គោល គណនេយ្យភាពសង្គមថ្នាក់ក្រុង ស្រុក ខណ្ឌ

៤).ចុះតាមដានត្រួតពិនិត្យ និងគាំទ្រដំណើរការអនុវត្តការងារគណនេយ្យភាពសង្គមថ្នាក់មូលដ្ឋាន

៥).រៀបចំកិច្ចប្រជុំទៀងទាត់ ត្រួតពិនិត្យ និងតាមដានការអនុវត្តការងារគណនេយ្យភាពសង្គមប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ។

៦).រៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ស្ដីពីវឌ្ឍនភាព និងបញ្ហាប្រឈម ស្ដីពីការអនុវត្តការងារ គណនេយ្យភាពសង្គម ជូនលេខាធិការដ្ឋាន គ.ជ.អ.ប

➢ **រដ្ឋបាលក្រុង ស្រុក ខណ្ឌ ៖** អនុវត្តសកម្មភាពគណនេយ្យភាពសង្គម មានដូចខាងក្រោម៖

១).រៀបចំសេចក្ដីសម្រេចបង្កើតក្រុមការងារគណនេយ្យភាពសង្គម ចាត់តាំងមន្ត្រីបង្គោល និងមន្ត្រីហិរញ្ញវត្ថុ ទទួលបន្ទុកអនុវត្តការងារគណនេយ្យភាពសង្គមថ្នាក់ក្រុង ស្រុក ខណ្ឌ។

២).រៀបចំបណ្ដុះបណ្ដាលបច្ចេកទេស ស្ដីពីការងារអនុវត្តគណនេយ្យភាពសង្គម ដល់អង្គភាពផ្ដល់សេវា

៣).រៀបចំកិច្ចប្រជុំត្រួតពិនិត្យ និងតាមដានការអនុវត្តការងារគណនេយ្យភាពសង្គមប្រចាំត្រីមាស ឆមាស និង ប្រចាំឆ្នាំ។

៤).រៀបចំទម្រង់ទិន្នន័យ ពិនិត្យមើលភាពត្រឹមត្រូវនៃការបំពេញទម្រង់ទិន្នន័យ ប្រមូល បញ្ចូលទិន្នន័យ និងផលិតទិន្នន័យលទ្ធផលបំពេញការងារ (Post-On) សម្រាប់បិទផ្សព្វផ្សាយព័ត៌មាន។

៥).ចុះត្រួតពិនិត្យដំណើរការបិទផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងតាមដានការអនុវត្ត

៦).រៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងអំពីដំណើរការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម លទ្ធផលនៃផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ) និងផែនការអនុវត្តបន្ត។

៧).សហការសម្របសម្រួល គាំទ្រដំណើរការអនុវត្តការងារគណនេយ្យភាពសង្គម ជាមួយនិងអង្គការសង្គមស៊ីវិលក្នុងក្រុង ស្រុក ខណ្ឌសាមី

៨).រៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈម ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ជូនរដ្ឋបាលរាជធានី ខេត្ត

៩).រៀបចំសេចក្តីសម្រេចបង្កើតគណៈកម្មាធិការផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ) ថ្នាក់ក្រុង ស្រុក ខណ្ឌ

១០).ចូលរួមកិច្ចប្រជុំជាប្រចាំរៀងរាល់ត្រីមាស របស់គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីត្រួតពិនិត្យ តាមដាន ការអនុវត្ត ផ.ស.រ.គ។

➢**រដ្ឋបាលឃុំ សង្កាត់** អនុវត្តសកម្មភាពគណនេយ្យភាពសង្គមដូចខាងក្រោម៖

១).រៀបចំសេចក្តីសម្រេចចាត់តាំងមន្ត្រីបង្គោលគណនេយ្យភាពសង្គមថ្នាក់ឃុំ សង្កាត់ (ជូនភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធ សេចក្តីសម្រេចចាត់តាំងមន្ត្រីបង្គោលគណនេយ្យភាពសង្គមថ្នាក់ឃុំ សង្កាត់)។

២).រៀបចំសេចក្តីសម្រេចបង្កើតគណៈកម្មាធិការផែនការសកម្មភាពរួម ស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ) ថ្នាក់ឃុំ សង្កាត់។

៣).ចូលរួមកិច្ចប្រជុំរៀងរាល់ត្រីមាស របស់គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីត្រួតពិនិត្យ តាមដាន ការអនុវត្ត ផ.ស.រ.គ។

➢**អង្គភាពផ្តល់សេវា (រដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព)** អនុវត្តសកម្មភាពគណនេយ្យភាពសង្គម និងមានតួនាទី ភារកិច្ចដូចខាងក្រោម៖

១).ផ្តល់ព័ត៌មានអំពីលទ្ធផលបំពេញការងារ ថវិកា ចំណូល ចំណាយ និងបិទផ្សព្វផ្សាយទិន្នន័យលទ្ធផលការបំពេញការងារ (Post-On)។

២).ចូលរួមកិច្ចប្រជុំវាយតម្លៃខ្លួនឯង និងកិច្ចប្រជុំរួម

៣).ចូលរួមជាសមាជិកគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ) និងគាំទ្រការអនុវត្ត ផ.ស.រ.គ។

៤).ចូលរួមកិច្ចប្រជុំរៀងរាល់ត្រីមាស របស់គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីត្រួតពិនិត្យ តាមដាន ការអនុវត្ត ផ.ស.រ.គ។

**II-ផ្នែកតម្រូវការ** (Demand side)

➢អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍មូលដ្ឋាន (CBO)

➢មន្ត្រីសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF)

➢ប្រជាពលរដ្ឋ និងតំណាងក្រុមប្រជាពលរដ្ឋ

**ផ្នែកតម្រូវការ អនុវត្តសកម្មភាពគណនេយ្យភាពសង្គម និងមានតួនាទី ភារកិច្ច ដូចខាងក្រោម៖**

១).ផ្តល់វគ្គបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF)

២).ផ្សព្វផ្សាយផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ( I4Cs)

៣).រៀបចំ និងចូលរួមកិច្ចប្រជុំដាក់ពិន្ទុសហគមន៍

៤).រៀបចំ និងចូលរួមកិច្ចប្រជុំរួម

៥).ចូលរួមជាសមាជិកគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម

៦).ផ្សព្វផ្សាយផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ)

៧).ចូលរួមកិច្ចប្រជុំត្រួតពិនិត្យ តាមដានការអនុវត្ត ផ.ស.រ.គ

៨).រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ផ្នែកតម្រូវការ ជូនអង្គការមិនមែនរដ្ឋាភិបាល និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**ប្រធានគ្រប់គ្រងគម្រោង** ISAF